# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Mar-2015, 11:33
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ:

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សារណារបស់ នួន ជា ទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង០០៤ និង ចម្លើយតបទៅនឹងការជូនដំណឹងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិអំពីការដាក់បង្ហាញឯកសារ**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ |
|---|---|
| **ក្រុមមេធាវីការពារក្តី នួន ជា** | **សហជនជាប់ចោទ** |
| សុន អរុណ | |
| Victor KOPPE | **សហព្រះរាជអាជ្ញា** |
| ព្រំ ផល្លា | **លោកស្រី ជា លាង** |
| សួន វិសាល | **លោក Nicholas KOUMJIAN** |
| លីវ សុវណ្ណា | **សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី** |
| Doreen CHEN | **PICH Ang** |
| Xiaoyang NIE | **Marie GUIRAUD** |

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ បានដាក់ឯកសារមួយនៅចំពោះអង្គជំនុំជម្រះនេះ ដោយបានផ្តល់ព័ត៌មានទាក់ទងនឹងការដាក់បង្ហាញដែលកំពុងតែបន្តនូវកំណត់ស្តាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង០០៣ និង០០៤[1]។ សហព្រះរាជអាជ្ញាអន្តរជាតិជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង[2] នៅក្នុងការទទួលស្គាល់ថា ការបង្ហាញ *"ពីការប្រឈមបច្ចុប្បន្នដើម្បីធានាការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស[3]"* ប៉ុន្តែខកខានមិនបានបញ្ជាក់បន្ថែមអំពីចរិតលក្ខណៈនៃការប្រឈមនោះ។ ក្នុងទស្សនៈរបស់សហមេធាវីការពារក្តីរបស់ នួន ជា ("ក្រុមមេធាវីការពារក្តី") ការពន្យល់បន្ថែម គឺសំខាន់ មិនត្រឹមតែជួយដល់អង្គជំនុំជម្រះក្នុងការក្តាប់បានរឹងមាំនូវស្ថានការណ៍នេះនៅពេលសម្រេចវិធីសាស្ត្រត្រឹមត្រូវដើម្បីបន្តនីតិវិធីទេ តែវានឹងធានាបានថា កំណត់ត្រាគ្រប់គ្រាន់ឆ្លុះបញ្ចាំងពីភាពលំបាកបំផុតដែលឯកសារត្រូវបានបង្ហាញនៅពេលនេះដល់ក្រុមមេធាវីការពារក្តី និងការជំនុំជម្រះជាទូទៅនៅក្នុងសំណុំរឿង០០២/០២ ផងដែរ។

២. អនុលោមតាមវិធាន៩២ ក្រុមមេធាវីការពារក្តីស្នើឱ្យពិចារណាថា ញត្តិទាក់ទងនឹងការបង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ដោយបានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងការប្រឈម និងការព្រួយបារម្ភធ្ងន់ធ្ងរ ដែលបង្កឡើងដោយការបង្ហាញឯកសារពីសំណុំរឿង ០០៣ និង០០៤ ដែលកំពុងបន្ត និងបានធ្វើសំណើជាច្រើនទាក់ទងនឹងបញ្ហានេះ។ ញត្តិនេះក៏ចាត់ទុកជាចម្លើយតបចំពោះការដាក់ឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

---

[1] ឯកសារ E319/14 ពត៌មាន និងការបំភ្លឺអំពីដំណើរការទាក់ទងនឹងការដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង០០២/០២ ក្នុងបរិបទនៃការស៊ើបសួរដែលកំពុងបន្តនៅក្នុងសំណុំរឿង០០៣ និង០០៤" ចុះថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ៩ ("ការដាក់បង្ហាញឯកសារ និងការបំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។

[2] ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីសវនាការនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ចៅក្រម Fenz រៀបរាប់ថា ស្ថានភាពលំបាកកំពុងត្រូវបានគ្រប់គ្រងក្នុងវិធីមួយដើម្បីធានាឱ្យការជំនុំជម្រះមានយុត្តិធម៌ និងឆាប់រហ័ស" (បញ្ជាក់បន្ថែម)។ សូមមើលឯកសារ **E1/264.1** ប្រតិចារិតសវនាការចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទំព័រ១៦។

[3] ឯកសារ E319/14 ការដាក់បង្ហាញឯកសារ និងការបំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅកថាខណ្ឌ១២។

## II. ព័ត៌មានបន្ថែមដែលផ្តល់ដោយក្រុមមេធាវីការពារក្តី

### ក. ឯកសារនានាដែលបានបង្ហាញមកទល់ពេលនេះ

៣. ចាប់តាំងពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១០២៤មក[4] ដោយគ្មានការយល់ព្រមយ៉ាងច្បាស់ពីសហព្រះរាជអាជ្ញាជាតិរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញដល់ក្រុមមេធាវីការពារក្តីនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥៥ ពីសំណុំរឿង ០០៣ និង០០៤។ កំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវបានបង្ហាញដោយមានការយល់ព្រមពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយផ្អែកលើមូលដ្ឋាននៃការពាក់ព័ន្ធជាក់ស្តែងដល់ករណី ០០២/០២។ ដូច្នេះគ្រាន់តែភាសាអង់គ្លេសកំណត់ហេតុស្តាប់ចម្លើយទាំងនេះមានកម្រាស់សរុប ២ ៨៣៨ ទំព័រ។ កំណត់ហេតុស្តាប់ចម្លើយភាគច្រើនត្រូវបានបង្ហាញកាលពីពីរសប្តាហ៍កន្លងទៅ ហើយក្រុមមេធាវីការពារក្តីទទួលបានចុងក្រោយនៅថ្ងៃអង្គារ៍ទី ៣ ខែ មីនា ឆ្នាំ ២០១៥ ថ្មីៗនេះ។ អនុលោមតាមសហព្រះរាជអាជ្ញាអន្តរជាតិ យ៉ាងហោចណាស់កំណត់ហេតុស្តាប់ចម្លើយចំនួន១៩០ នឹងត្រូវបង្ហាញបន្តទៀត ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយបន្ថែមនឹងត្រូវបង្ហាញ ខណៈដែលការស៊ើបសួរនៅក្នុងករណី០០៣ និង០០៤ កំពុងដំណើរការ។

៤. តាមរយៈការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី សហព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់សំណុំឯកសារជាច្រើនរបស់សំណុំរឿង ០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២/០២។ ម្យ៉ាងទៀតគាត់បានបង្ហាញចំណុចសំខាន់របស់សំណុំរឿង០០២ មិនចំពោះតែសំណុំរឿង០០២/០២ទេ តែក៏ជាចំណុចសំខាន់នៃបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១ដែរ *ដែលបញ្ហាទាំងអស់នេះស្ថិតនៅក្រោមការស៊ើបសួរយ៉ាងសកម្មនៅឡើយ* តាមរយៈការស៊ើបសួរកំពុងបន្តនៅក្នុងសំណុំរឿង០០៣ និង០០៤ ហើយស្របពេលជាមួយគ្នានេះចំណុច(aspects) *ទាំងនេះត្រូវបានជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងជាប់បណ្តឹងសាទុក្ខ*។ តាមការអង្កេតលើកាលបរិច្ឆេទនៃកំណត់ហេតុស្តាប់

---

[4] ឯកសារ E319/4 "ការជូនដំណឹងរបស់ នួន ជា ក្នុងការទទួលបានឯកសារដែលបង្ហាញទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខ ក្រាំងតាចាន់" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤។

ចម្លើយសាក្សីក្នុងសំណុំរឿង០០៣ និង០០៤ វាហាក់ដូចជាថាកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនោះ ត្រូវបានធ្វើឡើងនៅមុនសេចក្តីសន្និដ្ឋានបញ្ចប់ការស៊ើបសួរដោយនៅក្នុងសំណុំរឿង ០០២/០១ ហើយយឺតបំផុតបន្ទាប់ពីសាក្សីត្រូវបានផ្តល់ការបរិច្ឆេទឱ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការក្នុងសំណុំរឿង០០២/០២។

## ខ. ទំហំនៃឯកសារដែលបានបង្ហាញ

៥. ទំហំឯកសារដែលបានបង្ហាញមិនអាចបញ្ជាក់ឱ្យបានគ្រប់គ្រាន់បានទេ។ វាមិនមែនជាបញ្ហាអំពីចំនួនទេ ថ្វីបើចំនួននៃទិន្នន័យដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី មានចំនួនច្រើននិងលើសលុប។ ភស្តុតាងនេះមិនត្រឹមតែពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងចំណុចស្នូលនៃករណីរបស់ក្រុមមេធាវីការពារក្តីទេ ហើយវាមិនត្រឹមតែពាក់ព័ន្ធយ៉ាងសំខាន់ចំពោះសំណុំរឿង ០០២/០២ (និងបណ្តឹងសារទុក្ខនៅក្នុងករណី០០២/០១ទេ) ប៉ុន្តែបើពិនិត្យជាបឋម វាក៏ប៉ះពាល់ជាសារវ័ន្តដល់ចរិតលក្ខណៈនៃភស្តុតាងនៅក្នុងសំណុំរឿងទាក់ទងនឹងបញ្ហាសំខាន់ៗជាច្រើនដែលរងការជំទាស់។ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានបង្ហាញដែលក្រុមមេធាវីការពារក្តីបានពិនិត្យមកទល់នឹងពេលនេះ សាក្សីបាន:

(ក) ផ្តល់សក្ខីកម្មអំពីអត្ថិភាពនៃការបែងចែកជាក្រុមនៅក្នុង ប.ក.ក ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ព័ត៌មាននេះរួមមានសក្ខីកម្មដែលថាមានបួនក្រុម ("ក្រុមដែលជាប់ទាក់ទងជាមួយវៀតមិញ" "ខ្មែរក្រហមជាតិនិយម" "ខ្មែរក្រហមសីហានុ និយម" និង"ខ្មែរក្រហមពីចិន រួមមានប៉ុលពត", ព័ត៌មានអំពីក្រុមនានាជាពិសេសនៅភូមិភាគពាយព្យ និងភូមិភាគបូព៌ា និងព័ត៌មានកំណត់អត្តសញ្ញាណ សោ ភឹម ជាមេក្រុមមួយដែលបះបោលប្រឆាំងនឹងប៉ុលពត។

(ខ) រៀបរាប់លំអិតអំពីសកម្មភាពរបស់មេដឹកនាំជាច្រើននៃ ប.ក.ក រួមទាំង នួន ជា ហើយក៏ដូចជា តាម៉ុក សោ ភឹម និង រស់ ញឹម។

(គ) ពណ៌នាព្រឹត្តិការណ៍ជាច្រើនដែលរងការជំទាស់នៅទូទាំងការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ និងព្រឹត្តិការណ៍ដែលត្រូវបានជំនុំជម្រះរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ហើយនៅពេលនេះជាប់ក្នុងបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

(ឃ) ពិភាក្សាអំពីសកម្មភាពនានារបស់សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ សាក្សីដែលត្រូវបានផ្តល់កាលបរិច្ឆេទឲ្យផ្តល់សក្ខីកម្ម ត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្ម ឬត្រូវតែកោះហៅឲ្យផ្តល់សក្ខីកម្ម។

(ង) រៀបរាប់លំអិតអំពីរចនាសម្ព័ន្ធអំណាច និងការប្រព្រឹត្តទៅនៅភូមិភាគនិរតី និងបូព៌ា និង

(ច) ផ្តល់ភស្តុតាងដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអត្ថិភាពនៃគោលនយោបាយនានា ដូចជាការរៀបការដោយបង្ខំ និងការប្រព្រឹត្តមកលើជនជាតិវៀតណាម។

៦. ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានប៉ុនប៉ងកំណត់ថា តើផ្នែកការជំនុំជម្រះមួយណាដែលកំណត់ហេតុចម្លើយសាក្សីពាក់ព័ន្ធ និងដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅមុន ឬក្នុងអំឡុងផ្នែកសវនាការដែលពាក់ព័ន្ធ។ ប៉ុន្តែដោយយល់ឃើញថាវាជាការទទួលខុសត្រូវរបស់ក្រុមមេធាវីការពារក្តី ហើយមិនមែនសហព្រះរាជអាជ្ញាអន្តរជាតិទេ ក្នុងការកំណត់ករណីរបស់ក្រុមមេធាវីការពារក្តី ការវាយតម្លៃនេះជាញឹកញាប់មិនត្រឹមត្រូវ និងមិនមានប្រយោជន៍។ ឧទាហរណ៍ការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលក្រុមមេធាវីការពារក្តីមានលទ្ធភាពពិនិត្យ ជាញឹកញាប់មានព័ត៌មានដែលពាក់ព័ន្ធយ៉ាងសំខាន់ដល់ចំណុចជាច្រើននៃករណីរបស់មេធាវីការពារក្តី ជាជាងការដាក់កម្រិតត្រឹមតែផ្នែកជំនុំជម្រះបច្ចុប្បន្ន និងតម្រូវការវិភាគបន្ថែមនៅមុនផ្នែកជំនុំជម្រះបច្ចុប្បន្នអាចដំណើរការបាន។

៧. ការនេះបង្កើតឧបសគ្គបន្ថែមទៀតដល់ក្រុមមេធាវីការពារក្តី និងការជំនុំជម្រះ។ ឧទាហរណ៍ ផ្អែកលើព័ត៌មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលទើបតែបង្ហាញនាពេលថ្មីៗនេះ ក្រុមមេធាវីការពារក្តីបានដាក់សំណួរផ្សេងៗ ឬសំណួរបន្ថែមដល់អ្នកជំនាញម្នាក់ដែលបានផ្តល់សក្ខីកម្មរួចហើយ (Elizabeth Becker) ហើយអាចដាក់សំណួរដល់អ្នកទោស និងកម្មាភិបាលជាច្រើននាក់នៅមន្ទីរក្រាំងតាចាន់ដែលបានចូលខ្លួន-ជាសាក្សីដែលពេលនេះក្រុមមេធាវីការពារក្តី អាចនឹងស្នើសុំឲ្យកោះហៅសារជាថ្មី។ ទោះជាមានអ្វីកើតឡើងក៏ដោយក៏សវនាការត្រូវបន្ត ខណៈដែលភាគីមាញឹកជាមួយភស្តុតាងសំខាន់ៗ អាចប៉ះពាល់ភាពឆាប់រហ័សនៃ

ការជំនុំជម្រះ ជាពិសេសប្រសិនបើក្រុមមេធាវីការពារក្តីត្រូវបង្ខំចិត្តស្នើសុំឲ្យកោះហៅសាក្សី សារជាថ្មី។

៨. ស្របជាមួយគ្នានេះពិចារណាភាពពាក់ព័ន្ធនៃភស្តុតាងដែលបានបង្ហាញចំពោះអង្គហេតុដែលរងការ ជំទាស់នៅក្នុងសំណុំរឿង០០២/០១ ក្រុមមេធាវីការពារក្តីនៅពេលនេះត្រូវដាក់សំណើសុំបន្ថែម ភស្តុតាងទៅអង្គជំនុំជម្រះតុលាការកំពូល ដើម្បីដាក់ភស្តុតាងពាក់ព័ន្ធនៅអង្គជំនុំជម្រះនេះទាក់ ទងនឹងបណ្តឹងសាទុក្ខ។ ការនេះអាចបណ្តាលឲ្យពន្យារពេល និងបង្កភាពស្មុគស្មាញដល់កិច្ច ដំណើរការបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១។

## គ. ភស្តុតាងទាក់ទងនឹងខ្មែរក្រោម

៩.ម្យ៉ាងវិញទៀតវាសំខាន់ក្នុងការរំលេចថា ភស្តុតាងដែលបានបង្ហាញមិនបញ្ឈប់នៅត្រឹមវិសាល ភាពបច្ចុប្បន្ននៃសំណុំរឿង០០២នេះទេ។ ផ្ទុយទៅវិញសាច់រឿងស៊ីសង្វាក់គ្នានៅក្នុងកំណត់ ហេតុស្តាប់ចម្លើយសាក្សីនៅសំណុំរឿង០០៣ និង០០៤ គឺផ្តោតទៅលើបទពិសោធន៍នៃខ្មែរ (កម្ពុជា) ក្រោមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រុមមេធាវីការពារក្តីបានរំលេចរួចមកហើយ ក្នុងអំឡុងកិច្ចដំណើរការនិរតីវិធីជំនុំជម្រះក្នុងហាករណី០០២/០២ នៅថ្ងៃទី ១២ ខែ កុម្ភៈឆ្នាំ ២០១៥ ថាការផ្តោតមិនផ្លាស់ប្តូរនេះនាំឲ្យមានព្រួយបារម្ភធ្ងន់ធ្ងរ និងស្របច្បាប់អំពីភាពពាក់ ព័ន្ធរបស់ភស្តុតាងខ្មែរកម្ពុជានៅក្នុងករណី០០២/០២។ ដូចដែលមេធាវីការពារក្តីបានផ្តល់យោ បល់ ហើយអង្គជំនុំជម្រះសាលាដំបូងបានជ្រាបរួចមកហើយ ភាពពាក់ព័ន្ធនៃបទពិសោធន៍ខ្មែរ កម្ពុជាក្រោមនៅក្នុងសំណុំរឿង ០០២ ត្រូវបានជំទាស់យ៉ាងខ្លាំងយូរមកហើយ[5] ហើយ សហគមន៍ខ្មែរក្រោមបានទទួចដ៏ខ្លាំងក្លាដើម្បីឲ្យបទពិសោធន៍របស់ពួកគេ ត្រូវបានជំនុំជម្រះ នៅក្នុងបរិបទសំណុំរឿង០០២ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការប្រព្រឹត្តមិនត្រឹម ត្រូវលើក្រុមមនុស្សជាក់លាក់។ តែសហព្រះរាជអាជ្ញាជ្រើសរើសមិនដាក់បញ្ចូលនៅក្នុងដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ខ្លួននូវខ្មែរក្រោមជាក្រុមជាក់លាក់ ហើយក៏មិនបានដាក់ បញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែរ។ នៅពេលមួយអ្នកនាំពាក្យរបស់ អវតក Lars Olsen ប្រាប់សារព័ត៌មាន *Cambodia Daily* ទាក់ទងនឹងការខកខានរបស់ សហព្រះរាជអាជ្ញាមិនដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមថា:

[5] E1/262.1 "ប្រតិចារិតសវនាការថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ("ប្រតិចារិត") ចទំព័រ១៧ បន្ទាត់១៧, ទំព័រ១៧ បន្ទាត់២៥

វាមិនមែនជាកំហុសនោះទេ។ មានមូលហេតុថា ហេតុអ្វីបានជាពួកគេមិនដាក់។ ខ្ញុំដឹងមូលហេតុនោះ តែខ្ញុំមិនអាចប្រាប់អ្នកបានទេ[6]។

១០. ទោះបីជាមូលហេតុអ្វីក៏ដោយ លទ្ធផលគឺថាខ្មែរក្រោមមិនត្រូវបានកំណត់អត្តសញ្ញាណថាជាក្រុមគោលដៅនៅក្នុងដីកាដំណោះស្រាយទេ ឬជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែរ។ ការលើកឡើងពីខ្មែរក្រោមនៅក្នុងដីកាដំណោះស្រាយ គឺក្នុងលក្ខណៈកម្រិតយ៉ាងខ្លាំងដែរ។ ប៉ុន្តែដោយហេតុថាមានការផ្តោតជាហូរហែរទៅលើបទពិសោធន៍របស់ខ្មែរក្រោមនៅក្នុងការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលក្រុមមេធាវីការពារក្តីកំពុងបន្តរទទួលវាបង្កឱ្យមានកង្វល់ធ្ងន់ធ្ងរ និងធំឡើងដែលថា សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងពង្រីកវិសាលករណី00២/0២ តាមរយៈការជំនុំជម្រះបទពិសោធន៍ខ្មែរក្រោមថាស្ទើរតែ (quasi) ជាក្រុមគោលដៅ និងថាស្ទើរតែជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ តាមរយៈការដាក់បញ្ចូលដោយលួចលាក់នូវបទពិសោធន៍របស់ពួកគេទៅក្នុងបទពិសោធន៍ជនជាតិវៀតណាម បើទោះបីចរិតលក្ខណៈខុសគ្នាយ៉ាងច្បាស់របស់ក្រុមទាំងពីរនេះ ហើយបទពិសោធន៍របស់ខ្មែរក្រោមមិនត្រូវបានចោទប្រកាន់ច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយដែរ។ វាប្រាកដថា អត្តសញ្ញាណរបស់សាក្សីថាជាខ្មែរក្រោម មានភាពពាក់ព័ន្ធយ៉ាងហោចណាស់ក៏ចំពោះសហព្រះរាជអាជ្ញា មេធាវីដើមតំណាងឱ្យបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះសាលាដំបូងដែរ។ បើទោះបីបន្ទាប់ពីសាក្សីម្នាក់បានផ្តល់សក្ខីកម្មនៅពេលថ្មីៗនេះថា គាត់មិនដែលនិយាយថាគាត់ជាខ្មែរក្រោម ហើយផ្ទុយទៅវិញចាត់ទុកខ្លួនគាត់ជាខ្មែរលើ ក៏ចៅក្រម Lavergne បន្តសួរសាក្សីនេះថាតើគាត់ចាត់ទុកខ្លួនគាត់ថា ជាខ្មែរក្រោម[7]។

## ឃ. ឋានៈផ្លូវច្បាប់នៃកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បង្ហាញពីសំណុំរឿង00៣ និង00៤

១១. ក្រុមមេធាវីការពារក្តីព្រួយបារម្ភយ៉ាងខ្លាំងអំពីឋានៈផ្លូវច្បាប់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានដាក់បង្ហាញពីសំណុំរឿង00៣ និង00៤។ កង្វល់នេះទាក់ទងនឹងភវនីយភាព-

---

[6] D274/4/1.1.4 Julia Wallace, ចៅក្រមសាលាក្តីខ្មែរក្រហមនឹងមិនចោទឧក្រិដ្ឋកម្មប្រល័យសាសន៍លើខ្មែរក្រោម" *Cambodia Daily* ថ្ងៃទី២0 ខែមករា ឆ្នាំ២0១0។

[7] E1/262.1 ប្រតិចារិតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២0១៥ នៅទំព័រ៥៤ បន្ទាត់១៧-១៨ ("តើអ្នកចាត់ទុកខ្លួនឯងជាខ្មែរក្រោម?)

ដែលលើកឡើងពីសប្តាហ៍មុនតាមរយៈសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់តំណាងសហគមន៍អន្តរជាតិ[8]-ថាសំណុំរឿង០០៣ និង០០៤ នឹងមិនបញ្ជូនទៅជំនុំជម្រះទេ បើទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិប៉ុនប៉ងចេញដីកាដំណោះស្រាយដោយឯកតោភាគីក៏ដោយ។ ប្រសិនបើរឿងនេះវាកើតឡើងមែននោះក្រុមមេធាវីការពារក្តីមិនប្រាកដថា តើនឹងមានផលប៉ះពាល់អ្វី ប្រសិនបើមាន វាអាចប៉ះពាល់ដល់កំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើនៅក្នុងដំណាក់កាលស៊ើបសួរនៅក្នុងសំណុំរឿងនេះ ហើយថាវានឹងមានផលប៉ះពាល់យ៉ាងដូចម្តេចមកលើសំណុំរឿង០០២/០២នេះ ហើយថាតើផលប៉ះពាល់ទាំងនេះនឹងត្រូវគ្រប់គ្រងដោយរបៀបណា។

## ង. ភស្តុតាងក្រៅពីកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី

១២. ខ្លឹមសារនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានបង្ហាញនៅក្នុងសំណុំរឿង០០៣ និង ០០៤ បាននាំឲ្យក្រុមមេធាវីការពារក្តីមានកង្វល់បន្ថែមទៀត ជាពិសេសថាតើសំណុំរឿងទាំងនេះមានផ្ទុកនូវភស្តុតាងក្រៅពីកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែរទេ ដូចជាឯកសារដែលអាចពាក់ព័ន្ធចំពោះសំណុំរឿង០០២/០២នេះ។ ក្រុមមេធាវីការពារក្តីមិនមានជំហរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីបង្ហាញភស្តុតាងណាមួយទេ។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីជម្រុញអង្គជំនុំជម្រះសាលាដំបូងបង្គាប់ទៅសហព្រះរាជអាជ្ញាអន្តរជាតិឲ្យជូនដំណឹងដល់ភាគីថា តើភស្តុតាងបែបនេះមានដែរឬទេ ហើយប្រសិនបើមាន គឺស្នើឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់បង្ហាញភស្តុតាងឲ្យបានឆាប់តាមដែលអាចធ្វើបាន។

---

[8] សូមមើលឧទាហរណ៍ Kuch Naren "ហ៊ុន សែន ព្រមានពីសង្គ្រាមស៊ីវិល ប្រសិនបើ អវតក ធ្វើហួសពីដែនកំណត់" *Cambodia Daily*, ចុះផ្សាយថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ អាចរកបាននៅ: https://www.cambodiadaily.com/news/hun-sen-warns-of-civil-war-if-eccc-goes-beyond-limit-78757.
ស

## ច. លក្ខខណ្ឌនៃការហាមមិនឱ្យបង្ហាញភស្តុតាង មកលើក្រុមមេធាវីការពារក្តី

១៣. មិនត្រឹមតែក្រុមមេធាវីការពារក្តីប្រឈមជាមួយកាតព្វកិច្ចនៃការគ្រប់គ្រងភស្តុតាងដែលមានចំនួនច្រើនបែបនេះ ហើយក្រុមមេធាវីការពារក្តីក៏បានទទួលកំណត់ហេតុស្តាប់ចម្លើយដែលភ្ជាប់លក្ខខណ្ឌនៃការហាមមិនឱ្យបង្ហាញភស្តុតាង ដែលដាក់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ក្រុមមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឱ្យទទួលកំណត់ហេតុស្តាប់ចម្លើយជាទម្រង់អេឡិចត្រូនិកទេ ហើយក្រុមមេធាវីការពារត្រូវបានផ្តល់នូវសំណៅនៃកំណត់ហេតុស្តាប់ចម្លើយមួយច្បាប់ជាភាសានិមួយៗ ហើយអាចអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួន និងមិនមែនជាអ្នកហាត់ការងារទេ ដើម្បីពិនិត្យកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ដែលផ្ទុយនឹង អ្នកហាត់ការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពួកអាចចូលមើលកំណត់ហេតុស្តាប់ចម្លើយទាំងនោះដោយសេរី។ ដើម្បីអាចពិនិត្យ និងស្រាវជ្រាវព្រមៗគ្នាលើកំណត់ហេតុស្តាប់ចម្លើយដោយសមាជិកក្រុមមេធាវីការពារក្តី- ឧទាហរណ៍ដើម្បីប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ក្រុមមេធាវីការពារក្តីត្រូវបង្ខំចិត្តស្កេន ព្រីន ហើយបន្ទាប់មកធ្វើឱយក្លាយជាទំរង់អាចស្វែងរកពាក្យបាន ដែលជាដំណើរការប្រើប្រាស់ពេលវេលាច្រើន។

១៤. លក្ខខណ្ឌទាំងនេះមិនគួរត្រូវបានដាក់មកលើមេធាវីការពារក្តីដោយភាគីមួយដោយមិនមានក្នុងសំណុំរឿង០០២នោះទេ។ វាត្រូវបានមើលឃើញថា វាមិនមានភាពពាក់ព័ន្ធតទៅទៀតទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ជនសង្ស័យម្នាក់ពីក្នុងសំណុំរឿង ០០៣ និង ០០៤ កាលពីថ្ងៃ អង្គារ ទី ០៣ ខែ មីនា ឆ្នាំ២០១៥។ អាស្រ័យហេតុនេះហើយ មេធាវីការពារក្តីសូមទទូចឱ្យអង្គជំនុំជម្រះនេះ លើកលែងនូវលក្ខខណ្ឌនៃការបង្ហាញនេះ ដោយអនុលោមតាមអំណាចរបស់ខ្លួននៅក្រោមវិធាន ៨៥ ដើម្បី“ឱ្យមានលំដាប់លំដោយល្អក្នុងអំឡុងពេលសវនាការ”។

## ឆ. ពេលវេលា និងធនធាន មានកម្រិតសម្រាប់មេធាវីការពារក្តី

១៥. នៅជុំវិញការលំបាកនេះ កំណត់ហេតុការស្តាប់ចម្លើយសាក្សីជាច្រើន ត្រូវបានដាក់បង្ហាញដល់មេធាវីការពារក្តីមិនដល់ពីសប្តាហ៍មុននេះ និង នៅក្នុងសប្តាហ៍នេះផងដែរ នៅក្នុងពេលដែលមេធាវីការពារក្តីកំពុងមមារញឹកជាមួយនឹងកាលវិភាគសម្រាប់សវនាការដែលធ្វើឡើងចំនួនបួនថ្ងៃក្នុងមួយសប្តាហ៍នេះ។ ដូចដែលអង្គជំនុំជម្រះ និងភាគីបានឃើញហើយថា វាជាការសំខាន់

ណាស់ដែលសមាជិកទាំងអស់របស់មេធាវីការពារក្ដីចូលរួមក្នុងសវនាការជារៀងរាល់ថ្ងៃ ដោយសារតែភាពមានកម្រិតនៃកម្រិតថវិការសម្រាប់មេធាវីការពារក្ដី ដែលបានកំណត់មកលើចំនួនបុគ្គលិករបស់ខ្លួន។ តែផ្ទុយទៅវិញសហព្រះរាជអាជ្ញាអន្តរជាតិ យ៉ាងហោចណាស់ក៏មានព្រះរាជអាជ្ញាអន្តរជាតិដល់ទៅប្រាំមួយរូបកំពុងតែដឹកនាំសួរដេញដោលសាក្សី ព្រមទាំងមានបុគ្គលិកជំនួយដែលផ្លាស់ប្ដូរគ្នាជួយថែមទៀត។ បញ្ហានេះធ្វើឱ្យបុគ្គលិកទទួលប្រាក់ខែមានពេលតែមួយថ្ងៃក្នុងមួយសប្ដាហ៍ ថែមទាំងពេលល្ងាច និងពេលវេលាចុងសប្ដាហ៍ដើម្បីអានកំណត់ហេតុស្ដាប់ចម្លើយសាក្សីរាប់រយដែលត្រូវបានបង្ហាញ ហើយមានពេលតែមួយថ្ងៃគត់ក្នុងមួយសប្ដាហ៍នៅក្នុងការពិភាក្សាជាមួយ នួន ជា អំពីកំណត់ហេតុទាំងនេះដើម្បីទទួលបានការណែនាំរបស់គាត់។ បុគ្គលិករបស់មេធាវីការពារក្ដីត្រូវតែធ្វើការព្រមគ្នានិងការរៀបចំសម្រាប់សវនាការរាល់ថ្ងៃ ដោយមិនមានការជួយពីកម្មសិក្សា និងនៅក្នុងពេលដែលកំពុងប្រឈមនឹងអ្វីដែលជាការបង្ហាញថ្មីៗ ដែលនឹងត្រូវបញ្ជូនមកពីសហព្រះរាជអាជ្ញាអន្តរជាតិ។

១៦. ស្ថិតនៅក្រោមកាលៈទេសៈនេះ មេធាវីការពារក្ដីមិនអាចអាន ដោយមិនទាន់គិតដល់ការវិភាគដ៏ត្រឹមត្រូវនូវកំណត់ហេតុទាំងនោះផង បើទោះជាខ្លួនបានខំប្រឹងអស់ពីសម្ថភាពរបស់ខ្លួននៅក្នុងការបន្តការយល់ដឹងអំពីសំណុំរឿងនៅក្នុងពេលសំណុំរឿង00២។ ប្រការនេះធ្វើឱ្យប៉ះពាល់កាន់តែខ្លាំងឡើង ដោយសារតែពេលវេលាមានកំណត់ហួសហេតុ ដែលត្រូវបានផ្ដល់ដល់ភាគីដើម្បីត្រួតពិនិត្យកំណត់ហេតុទាំងនេះ។ មេធាវីការពារក្ដីបានកត់សំគាល់ថា អង្គជំនុំជម្រះបានផ្អាកសវនាការសម្រាប់រយៈពេលពីរថ្ងៃ ដើម្បីឱ្យភាគីមានពេល "យល់ដឹង" ដោយខ្លួនឯងអំពីកំណត់ហេតុថ្មីៗដែលត្រូវបានបង្ហាញនេះ។ ដោយគិតតែចំពោះកំណត់ហេតុដែលបានផ្ដល់ជូនតែក្នុងខែ កុម្ភៈ តែមួយគត់ វាមានរហូតទៅដល់ ២ ៨៣៨ ទំព័រឯណោះ (តែជាភាសាអង់គ្លេស) គឺថា យើងត្រូវចំណាយពេលវេលាមួយនាទីសម្រាប់មួយទំព័រដោយមិនដេកសម្រាប់រយៈពេលពីរថ្ងៃ[9]។ ជាការច្បាស់ណាស់ពេលវេលានេះ គឺមិនអាចធ្វើទៅរួចទេ។ ប្រសិនបើការដាក់បង្ហាញថ្មីនឹងត្រូវបន្តដូចអ្វីដែលកំពុងមាននេះ មេធាវីការពារក្ដីនឹងបង្ខំខ្លួនក្នុងការស្នើសុំធនធានបន្ថែម ដើម្បីបន្តឱ្យខ្លួនយល់ដឹងអំពីសំណុំរឿង។

---

[9] ផ្ទុយទៅវិញ មេធាវីការពារក្ដីកត់សម្គាល់ថា អង្គជំនុំជម្រះបានឆ្លើយតបទៅនឹងឯកសារដែលបង្ហាញជាលើកដំបូង ដែលមានកម្រាស់ ៥១៥ទំព័រជាភាសាអង់គ្លេស ដោយបានផ្អាកសវនាការក្នុងរយៈពេលមួយសប្ដាហ៍។

## ជ. ការរំលោភកាន់តែខ្លាំងដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានកាត់សេចក្ដីដោយយុត្តិធម៌

១៧. ការដាក់បង្ហាញកំពុងកើតមាននេះ គឺរំលោភដល់សិទ្ធិជាមូលដ្ឋានរបស់ នួន ជា ក្នុងការទទួលបានកាត់សេចក្ដីដោយយុត្តិធម៌ ក្នុងការយល់ដឹងអំពីភស្តុតាងប្រឆាំងនឹងរូបគាត់ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដីរបស់ខ្លួន និងសមភាពក្នុងការតតាំងក្ដី។ ជាងនេះទៅទៀតនោះ ការរំលោភដ៏ធ្ងន់ធ្ងរគឺកាន់តែអាក្រក់បើពិចារណាក្នុងបរិបទនេះ។ ដូចដែលបានលើកឡើងជាច្រើននៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់យើងខ្ញុំ[10] ដែលកំពុងត្រូវពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូល ដោយសារតែនៅក្នុងសំណុំរឿង ០០២/០១ គឺមានកំហុស និង រំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការរៀបចំពេលបច្ចុប្បន្ននេះបង្ហាញ គ្មានការផ្លាស់ប្ដូរអ្វីនោះទេសម្រាប់សំណុំរឿង ០០២/០២។ តែផ្ទុយទៅវិញ ស្ថានភាពបែរជារិតតែអាក្រក់ ដោយមានការរំលោភជាសំខាន់ទៅដល់សិទ្ធិជាមូលដ្ឋានរបស់ នួន ជា ដូចដែលកំពុងកើតមាននេះ ដោយបន្ថែមទៅលើអ្វីដែលជាការរំលោភជាធម្មតាជារៀងរាល់ថ្ងៃ។ ការព្រួយបារម្ភរបស់មេធាវីការពារក្ដី ដែលបានលើកឡើងនៅក្នុងបណ្ដឹងជំទាស់ចៅក្រម[11] គឺត្រូវបានឃើញជារូបរាង មតិដោយឡែករបស់ចៅក្រម Downing ដែលមាន "មូលដ្ឋានសម្រាប់សន្និដ្ឋានថា អ្នកអង្កេតសមហេតុផល ដែលត្រូវបានជូនដំណឹងត្រឹមត្រូវ នឹងយល់ថា ជាការលម្អៀង" ពីចៅក្រមប្រធាន និល ណុន ចៅក្រម សុខន ចៅក្រម Lavergn និងចៅក្រម ឧត្តរា[12] ដែលកំពុងបង្ហាញជារៀងរាល់ថ្ងៃ។

១៨. ជាចុងក្រោយ មេធាវីការពារក្ដីមានបំណងចង់បង្ហាញជាពិសេសថា សហព្រះរាជអាជ្ញាបានស្នើសុំកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ថា "យ៉ាងហោចណាស់មានសាក្សីចំនួន ១៣ នាក់នៃសាក្សីរបស់ខ្លួន [...] នៅលើមូលដ្ឋាននៃភស្តុតាងថ្មី ឬក៏កំណត់ហេតុថ្មីនៅក្នុងសំណុំ

---

[10] ឯកសារ F16 "បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២" ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។

[11] ឯកសារ E314/6 "បណ្ដឹងជំទាស់ចៅក្រមរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean Marc Lagvergne និងចៅក្រម យូរ ឧត្តរា" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[12] ឯកសារ E314/12/1 "សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម" ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ផ្នែកខ្លះនៃមតិដោយឡែករបស់ចៅក្រម Rowan Downing កថាខណ្ឌ ៤០។

រឿង ០០៣ ឬ ០០៤" ភាពពាក់ព័ន្ធដែលត្រូវបានអនុញ្ញាតឲ្យសង្ខេបយ៉ាងខ្លី[13]។ អាស្រ័យហេតុនេះហើយ សហព្រះរាជអាជ្ញា មានពេលវេលាយ៉ាងវែងក្នុងការរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនទៅលើកំណត់ហេតុដែលមិនទាន់ដាក់បង្ហាញ ហើយដែលបានធ្វើឡើងបានយ៉ាងល្អនៅមុនពេលចាប់ផ្តើមសំណុំរឿង ០០២/០២ និងក្រោយមកបានដាក់បង្ហាញដល់មេធាវីការពារក្តី។ នៅក្នុងស្ថានភាពបែបនេះ គោលជំហររបស់មេធាវីការពារក្តីគឺដូចជាមនុស្សដែលគេចងមុខហើយវ៉ៃជាមួយគូរភាគីដែលមិនការកម្រិតដូចនេះ។ វាផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថាវាអាច "ធានាបានទាំងស្រុងនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីមួយត្រឹមត្រូវ"[14] តែការរៀបចំនៃការបង្ហាញឯកសារនោះ គឺវាគ្រាន់តែជាការរំលោភដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវ និងជាពិសេសចំពោះសិទ្ធិទាំងបីដែលបានលើកឡើងខាងលើ។ នៅក្នុងបរិបទនេះ បើទោះជាសហព្រះរាជអាជ្ញាបានជូនដំណឹង ឬមិនបានជូនដំណឹងអំពីការដាក់បង្ហាញឯកសារជាមុនដែលបានខិតខំយ៉ាងច្រើនក្នុងការពន្យល់ពីអ្វីដែលបានកើតឡើងក៏ដោយ ក៏វាមិនមានជាហេតុបច្ច័យនោះទេ។

## III. **ដំណោះស្រាយ**

១៩. សម្រាប់ហេតុផលដូចបានរៀបរាប់ខាងលើ សហមេធាវីការពារក្តីរបស់ នួន ជា ស្នើសុំថា

(ក) ផ្អាកសវនាការក្នុងសំណុំរឿង ០០២/០២ ជាបន្ទាន់ ឬជាជម្រើសម្យ៉ាងទៀត ស្តាប់សក្ខីកម្មតែ (កម្មាភិបាល) សាក្សីនៅក្នុងវិសាលភាពដំបូងដែលមិនមានតួនាទីជាអ្នកដឹកនាំ (គឺមានន័យថា កុំទាន់ស្តាប់សក្ខីកម្មសាក្សី 2-TCW 803 និង 2-TCW 809 ។

---

[13] E307/3/2 "សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសាក្សីដែលបានស្នើសុំសម្រាប់សវនាការអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២" ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៤ បានពិភាក្សាក្នុង E319/14 ការបញ្ជាក់របស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការដាក់បង្ហាញឯកសារ កថាខណ្ឌទី៣។

[14] E319/14 "ព័ត៌មាន និងការបំភ្លឺអំពីដំណើរការនៃការដាក់បង្ហាញឯកសារក្នុងសំណុំរឿង ០០២/០២ ក្នុងបរិបទនៃកិច្ចស៊ើបសួរដែលកំពុងធ្វើនៃសំណុំរឿង ០០៣ និង ០០៤, កថាខណ្ឌ១៣។

(ខ) កំណត់កាលវិភាគសម្រាប់ការប្រជុំរៀបចំសវនាការ សម្រាប់ការពិភាក្សាជាសាធារណៈដោយមានការចូលរួមរបស់ភាគី អំពីអំណើរការដាក់បង្ហាញឯកសារ និង មធ្យោបាយក្នុងពេលខាងមុខ

(គ) ធានាការពិភាក្សាជាមួយមេធាវីការពារក្តីក្នុងការកំណត់រយៈពេលសម្រាប់ការផ្អាកសវនាការ ដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្តីពិនិត្យកំណត់ហេតុទាំងនោះ។

(ឃ) ដោយពិចារណាអំពីលំដាប់លំដោយសវនាការក្នុងសំណុំរឿង០០២/០២ ជ្រើសរើសវគ្គសវនាការនៅពេលខាងមុខដែលមិនប៉ះពាល់ ដែលបណ្តាលមកពីការដាក់បង្ហាញឯកសារដែលកំពុងកើតមាន (ដូចជាការដ្ឋានទំនប់ ១ មករា) និងធានាថា ភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យកំណត់ហេតុឲ្យបានមុនពេលចាប់ផ្តើមនូវវគ្គសវនាការដែលប៉ះពាល់មកពីការដាក់បង្ហាញនេះ។

(ង) ធានាដល់ភាគីដែលថា ខ្មែរក្រោម នឹងមិនរាប់បញ្ចូល “ស្ទើរតែ” ជាក្រុមគោលដៅក្នុងសវនាការសំណុំរឿង ០០២/០២។

(ច) បង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ជូនដំណឹងដល់ភាគីថា តើអាចមានភស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយប្រសិនបើមាន ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញឯកសារទាំងនេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ និង

(ឆ) លើកលែងនូវលក្ខខណ្ឌហាមឃាត់អំពីការការបង្ហាញឯកសារមកលើមេធាវីការពារក្តីទាក់ទងនឹងការចូលមើល និងការប្រើប្រាស់ឯកសារក្នុងសំណុំរឿង ០០៣ និង ០០៤។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE